# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ២៧៣/១៥ គ.ជ.ប

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តគោលការណ៍សមាហរណកម្មមន្ត្រីអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត ទៅក្នុងក្របខណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ផ្អែកតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ បានកំណត់ថា មន្ត្រី បុគ្គលិក គ.ជ.ប គឺជាមន្ត្រី បុគ្គលិកស្ថិតក្នុងក្របខណ្ឌនៃលក្ខន្តិកៈដោយឡែកមួយ។ ចំណែកឯព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការនៃ គ.ជ.ប ក៏បានចូលជាធរមានតាំងតែពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/៦៤៨ រួចហើយដែរ។ ទន្ទឹមនឹងនេះ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និងសេចក្តីសម្រេចស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខបទៅក្នុងក្របខណ្ឌមន្ត្រីរាជការនៃ គ.ជ.ប ក៏បានកសាងរួចរាល់ជាស្ថាពរហើយ។ ហេតុនេះ ដើម្បីជម្រុញដំណើរការធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌថ្មីឱ្យបានត្រឹមត្រូវ ស្របតាមលិខិតបទដ្ឋានគតិយុត្តនានាដែលបានកំណត់ គ.ជ.ប សូមណែនាំដល់គណៈកម្មការសមាហរណកម្មនូវនីតិវិធីនៃការអនុវត្តគោលការណ៍សមាហរណកម្មតាមខ្លឹមសារដូចខាងក្រោម៖

ការធ្វើសមាហរណកម្មចែកចេញជា៣ (បី) ប្រភេទ រួមមាន ការធ្វើសមាហរណកម្មតាមមុខតំណែង តាមអតីតភាពការងារ និងតាមកម្រិតសញ្ញាបត្រ។

### ១- ការធ្វើសមាហរណកម្មតាមមុខតំណែង តាមអតីតភាពការងារ និងតាមកម្រិតសញ្ញាបត្រ

ក- មន្ត្រីដែលធ្វើសមាហរណកម្មតាមមុខតំណែង

ការធ្វើសមាហរណកម្មតាមមុខតំណែង គឺការធ្វើសមាហរណកម្មមន្ត្រីស្ថិតក្នុងមុខតំណែងដែលមានឈ្មោះបម្រើការងារនៅក្នុង គ.ជ.ប ចាប់ពីថ្នាក់មន្ត្រីជំនាញ ឬមានឋានៈស្មើនឹងមុខតំណែងនេះឡើងទៅដល់ថ្នាក់អគ្គលេខាធិការ ដោយត្រូវអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ៩ នៃជំពូកទី២ (ការធ្វើសមាហរណកម្មតាមមុខតំណែង) នៃសេចក្តីសម្រេចស្តីពីគោលការណ៍សមាហរណកម្ម។

ការផ្ទេរបញ្ចូលទៅក្នុងថ្នាក់នៃឋានន្តរសក្តិនីមួយៗ ត្រូវអនុវត្តទៅតាមតារាងឧបសម្ព័ន្ធទី១ **ក** តារាងឧបសម្ព័ន្ធទី១ **ខ** តារាងឧបសម្ព័ន្ធទី១ **គ** និងតារាងឧបសម្ព័ន្ធទី២ **ក** តារាងឧបសម្ព័ន្ធទី២ **ខ** និងតារាងឧបសម្ព័ន្ធទី២ **គ** នៃសេចក្តីសម្រេចស្តីពីគោលការណ៍សមាហរណកម្ម។

ខ- មន្ត្រីដែលត្រូវសមាហរណកម្មតាមអតីតភាពការងារ

ការធ្វើសមាហរណកម្មតាមអតីតភាពការងារ គឺការធ្វើសមាហរណកម្មមន្ត្រីដែលមានឈ្មោះបម្រើការងារនៅក្នុង គ.ជ.ប ចាប់ពីថ្នាក់លេខាធិការ ឬការីកុំព្យូទ័រចុះក្រោម ដោយត្រូវអនុវត្តទៅតាមខ្លឹមសារដូចមានចែងក្នុងប្រការ១០ ប្រការ១១ និងប្រការ១២ នៃជំពូកទី៣ (គោលការណ៍សមាហរណកម្មតាមអតីតភាពការងារ) នៃសេចក្ដីសម្រេចស្ដីពីគោលការណ៍សមាហរណកម្ម។

គ- មន្ត្រីដែលត្រូវសមាហរណកម្មតាមកម្រិតសញ្ញាបត្រ

មន្ត្រីចាប់ពីថ្នាក់ប្រធានការិយាល័យ ឬមានឋានៈស្មើនឹងមុខតំណែងនេះចុះក្រោម មានសញ្ញាបត្របរិញ្ញាបត្រ ឬមានសញ្ញាបត្រសមមូល ត្រូវផ្ទេរបញ្ចូលទៅក្នុង ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ៤ នៃក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់។ គណៈកម្មការសមាហរណកម្មត្រូវធ្វើបញ្ជីរាយនាមមន្ត្រីប្រភេទនេះ ដោយភ្ជាប់សញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល និងសំណើ ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច។

មន្ត្រីចាប់ពីថ្នាក់លេខាធិការ ឬការីកុំព្យូទ័រចុះក្រោម មានសញ្ញាបត្រទុតិយភូមិបូកវគ្គបណ្ដុះបណ្ដាលរយៈពេល២ (ពីរ) ឆ្នាំ (បរិញ្ញាបត្ររង) ត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរសក្តិក្រមការ ថ្នាក់លេខ៤ នៃក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម។ គណៈកម្មការសមាហរណកម្មត្រូវធ្វើបញ្ជីរាយនាមមន្ត្រីប្រភេទនេះ ដោយភ្ជាប់សញ្ញាបត្របរិញ្ញាបត្ររង ឬសញ្ញាបត្រសមមូល និងសំណើ ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច។

## ២- មន្ត្រីដែលមានក្របខណ្ឌជាមន្ត្រីរាជការក្របខណ្ឌផ្សេងទៀត

ចំពោះករណីដែលមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី៣ នៃប្រការ១៤ នៃជំពូកទី៤ (បទប្បញ្ញត្តិដោយឡែក) នៃសេចក្ដីសម្រេចស្ដីពីគោលការណ៍សមាហរណកម្ម ត្រូវអនុវត្តដូចខាងក្រោមៈ

មន្ត្រីដែលមានក្របខណ្ឌជាមន្ត្រីរាជការក្របខណ្ឌផ្សេងទៀតដែលមានបំណងបម្រើការងារជា អ.គ.ជ.ប ឬមន្ត្រីដែលមិនមកបម្រើការងារជា អ.គ.ជ.ប ត្រូវដាក់ពាក្យសុំបម្រើការងារ ឬពាក្យសុំឈប់បម្រើការងារនៅ គ.ជ.ប យ៉ាងយូរត្រឹមថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥។

មន្ត្រីដែលមានបំណងបន្តបម្រើការងារនៅ គ.ជ.ប ត្រូវផ្ទេរក្របខណ្ឌចេញពីក្រសួងស្ថាប័នដើម តាមនីតិវិធីជាធរមាន។

គណៈកម្មការសមាហរណកម្មត្រូវធ្វើបញ្ជីរាយនាមមន្ត្រីប្រភេទនេះ ដោយភ្ជាប់សំណើ ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច។

**៣- មន្ត្រីដែលមានអាយុលើសពីការកំណត់ (៦០ឆ្នាំ)**

មន្ត្រីដែលមានអាយុលើសពី៦០ (ហុកសិប) ឆ្នាំ ត្រូវធ្វើពាក្យសុំបន្តធ្វើការងារនៅ គ.ជ.ប តាមនីតិវិធីជាធរមាន។

ទទួលបានសេចក្តីណែនាំនេះ គណៈកម្មការសមាហរណកម្មត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៥

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ស៊ិក ប៊ុនហុក**